00269793

C26/5/9

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / JAN / 2009
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fuy

| | |
|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ: | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៥) |
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម ន័យ ថុល |
| | ចៅក្រម Katinka LAHUIS |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ: | ៨ មករា ២០០៩ |

**សាធារណៈ**

**សេចក្តីសម្រេចលើពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្នើពន្យារពេលក្នុងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Vincent de WILDE d'ESTMAEL

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 08 / JAN / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fuy

**សហមេធាវីការពារក្តី**

ស សូវ៉ាន
Jacques VERGÉS

PRE-TRIAL CHAMBER / CHAMBRE PRÉLIMINAIRE

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ទទួលបាន "ពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្នើពន្យារពេលក្នុងការដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ **ខៀវ សំផន** ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន" ("ពាក្យសុំ")។ ពាក្យសុំនេះបានដាក់នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨។

២. នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨, អង្គបុរេជំនុំជម្រះ បានបង្គាប់ភាគីនានាឱ្យដាក់សេចក្តីសន្និដ្ឋានតបចំពោះពាក្យសុំត្រឹមថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ ត្រឹមម៉ោង ១២:០០ ថ្ងៃត្រង់។

៣. នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩, សហមេធាវីការពារក្តីរបស់ជនត្រូវចោទ បានដាក់សេចក្តីសន្និដ្ឋានតបមួយ ដែលនៅក្នុងនោះ សហមេធាវីការពារក្តីបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ត្រូវដោះស្រាយជាបន្ទាន់ ហើយគូសបញ្ជាក់ថា ហេតុផលនៅក្នុងពាក្យសុំនេះ គឺផ្អែកលើកង្វះខាតធនធានក្នុងការបកប្រែ។ សហមេធាវីការពារក្តីចង្អុលបញ្ជាក់ថា ប្រសិនបើទទួលយកពាក្យសុំនេះរយៈពេលសែសិបពីរ (៤២) ថ្ងៃ នៃចន្លោះពេលដាក់សារណាបណ្តឹងឧទ្ធរណ៍ និងពេលដាក់សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា នឹងត្រូវផុត ដោយសារតែការបកប្រែលើសារណាបណ្តឹងឧទ្ធរណ៍នេះជាភាសាអង់គ្លេស បានចំណាយរយៈពេលម្ភៃ (២០) ថ្ងៃរួចទៅហើយ។ ដោយហេតុនេះ សហមេធាវីការពារក្តី ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលស្គាល់ការពន្យារពេលនេះ ដោយសារមូលហេតុនៃកង្វះខាតបុគ្គលិក និងមធ្យោបាយបកប្រែ, សហមេធាវីការពារក្តីទុកបញ្ហានៃការពន្យារពេលនេះ ឱ្យចៅក្រមជាអ្នកសម្រេច។

៤. ដើមបណ្តឹងរដ្ឋប្បវេណី មិនបានដាក់សេចក្តីសន្និដ្ឋានតបឡើយ។

៥. អង្គបុរេជំនុំជម្រះសង្កេតឃើញថា "សារណាបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ចំពោះដីកាសម្រេចបន្តចិរវេលាឃុំខ្លួនបណ្តោះអាសន្ន" ("បណ្តឹងឧទ្ធរណ៍") បានដាក់ជូនអង្គបុរេជំនុំជម្រះនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ ជាភាសាខ្មែរ និងបារាំង។ បណ្តឹងឧទ្ធរណ៍នេះ បានជូនដំណឹងដល់សហព្រះរាជអាជ្ញាជាភាសាអង់គ្លេស នៅថ្ងៃទី២៣ ខែធ្នូ។ ហេតុដូច្នេះ រយៈពេលដប់ប្រាំ (១៥) ថ្ងៃ សម្រាប់សហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានតប នឹងផុតនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០០៩។

00269795



៦. នៅក្នុងពាក្យសុំ សហព្រះរាជអាជ្ញាស្នើសុំឱ្យផ្តល់នូវពេលវេលាបន្ថែមចំនួនមួយ (១) សប្តាហ៍ ដើម្បីដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួន ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍។ ដូច្នេះ កាលបរិច្ឆេទកំណត់នឹងពន្យាររហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៨។

៧. ពាក្យសុំនេះបានធ្វើឡើងដោយហេតុថា ពេលវេលាបន្ថែម គឺទាមទារឱ្យមាន ដើម្បីបកប្រែសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាតបទៅនឹងបណ្តឹងឧទ្ធរណ៍។ សហព្រះរាជអាជ្ញាចង្អុលបញ្ជាក់ថា អ្នកបកប្រែផ្ទៃក្នុងរបស់ខ្លួន នឹងមិនអាចធ្វើការបកប្រែឯកសារនេះ មុនកាលបរិច្ឆេទកំណត់ឡើយ ពីព្រោះតែតម្រូវការបកប្រែសេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍ចំនួនប្រាំមួយ (៦) ទៀត គឺត្រូវនឹងកាលបរិច្ឆេទកំណត់ក្នុងពេលស្ទើរតែទន្ទឹមគ្នាតែម្តង។

៨. សហព្រះរាជអាជ្ញាក៏គូសបញ្ជាក់ផងដែរថា អវត្តមាននៃមន្ត្រីអ្នកច្បាប់ ដែលមានការអនុញ្ញាតជាមុននៅក្នុងពេលវិសម្មកាលរបស់តុលាការ បានធ្វើឱ្យលទ្ធភាពរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍មានការថយចុះបន្ថែមទៀត។

៩. អនុលោមតាមវិធាន ៣៩(៤)(ក) នៃវិធានផ្ទៃក្នុង, តាមរយៈបណ្តឹងរបស់ភាគីពាក់ព័ន្ធ អង្គបុរេជំនុំជម្រះអាចពន្យារពេលកំណត់។

១០. អង្គបុរេជំនុំជម្រះទទួលស្គាល់ការពិតថា វិសម្មកាលរបស់តុលាការរយៈពេលបួន (៤) ថ្ងៃ និង កាលបរិច្ឆេទកំណត់ទន្ទឹមគ្នា ចំពោះការដាក់សេចក្តីសន្និដ្ឋានមួយចំនួន បានកាត់បន្ថយរយៈពេលកំណត់យ៉ាងច្រើនសម្រាប់សហព្រះរាជអាជ្ញា ក្នុងការរៀបចំសេចក្តីសន្និដ្ឋានរបស់ខ្លួនតបទៅនឹងបណ្តឹងឧទ្ធរណ៍ ជាពីរ (២) ភាសាការងារ។

១១. ទោះបីជាយ៉ាងណាក៏ដោយ ដោយពិចារណាសេចក្តីសង្កេតនានារបស់ក្រុមមេធាវីការពារក្តី និងដោយពិចារណាថា ពាក្យសុំនេះពាក់ព័ន្ធនឹងសេរីភាពរបស់បុគ្គល, អង្គបុរេជំនុំជម្រះយល់ឃើញថា ហេតុផលរបស់សហព្រះរាជអាជ្ញា មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការពន្យារកាលបរិច្ឆេទកំណត់ រហូតដល់មួយសប្តាហ៍ពេញនោះឡើយ។ អង្គបុរេជំនុំជម្រះគូសបញ្ជាក់ថា នីតិវិធីនានាមិនត្រូវធ្វើឱ្យមានការយឺតយ៉ាវដោយសារកង្វះខាតនៃធនធានបកប្រែ ឡើយ។

១២. ដូច្នេះអង្គបុរេជំនុំជម្រះ នឹងពន្យារកាលបរិច្ឆេទកំណត់សម្រាប់សហព្រះរាជអាជ្ញា ក្នុងការដាក់សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍ រហូតដល់ថ្ងៃសុក្រ ទី៩ ខែមករា ឆ្នាំ២០០៩ វេលាម៉ោង ៤:០០ រសៀល។

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះ

**ទទួល** យកពាក្យសុំ។

**បង្គាប់** សហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានតបរបស់ខ្លួន ចំពោះបណ្តឹងឧទ្ធរណ៍ **ត្រឹមថ្ងៃទី៩ ខែមករា ឆ្នាំ២០០៩ ត្រឹមម៉ោង ៤:០០ រសៀល**។

ភ្នំពេញ ថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

**ប្រាក់ គឹមសាន**